## ខ និង លក្ខខណ្ឌនៃកិច្ចព្រមព្រៀងអតិថិជនរបស់តេឡេស៊ឺហ្វ (TELESURF)

ទាំងនេះគឺជា *ខ និងលក្ខខណ្ឌ*ដែលក្រុមហ៊ុន **ខេម ជី អេស ចំកាត់** (CamGSM Company Limited) ដែលតទៅនេះហៅកាត់ថា "**យើង**" ឬ "**តេឡេស៊ឺហ្វ**" នឹងផ្តល់សេវាបញ្ជូនពត៌មានឆាប់រហ័សដល់អ្នក ដូចបានរៀបរាប់នៅក្នុងប្រការ ១ នៃកិច្ចព្រម ព្រៀងនេះ ។ ពាក្យថា "**អ្នក**" ឬ "**របស់អ្នក**" មានន័យថាក្រុមហ៊ុន ឬបុគ្គលដែលចុះហត្ថលេខាលើ*កិច្ចព្រមព្រៀងអតិថិជន តេឡេស៊ឺហ្វ* ។ ហត្ថលេខារបស់អ្នកនៅលើ*កិច្ចព្រមព្រៀងតេឡេស៊ឺហ្វ* បញ្ជាក់ថាអ្នកយល់ព្រម ឬក្រុមហ៊ុនដែលអ្នកតំណាង យល់ព្រមអនុវត្តតាម និងជាប់កាតព្វកិច្ចដោយខ និងលក្ខខណ្ឌទាំងនេះ ។ ខនិងលក្ខខណ្ឌទាំងនេះ ព្រមទាំង*កិច្ចព្រមព្រៀង អតិថិជនតេឡេស៊ឺហ្វ* នឹងបង្កើតបានជា "**កិច្ចព្រមព្រៀង**" រវាងយើង និងអ្នក ។ ដើម្បីប្រើប្រាស់សេវាដែលយើងនឹងផ្តល់ឱ្យ ក្រោមកិច្ចព្រមព្រៀងនេះ អ្នកចាំបាច់ត្រូវជួលឧបករណ៍បញ្ជូនពត៌មានឆាប់រហ័សពីយើង ក្រោមលក្ខខណ្ឌដែលមានចែងនៅ ក្នុងប្រការ ៣ នៃកិច្ចព្រមព្រៀងនេះ ។ អ្នកក៏ចាំបាច់ត្រូវមានឧបករណ៍ផ្សេងៗទៀត ដូចមានចែងនៅក្នុងប្រការ ១ នៃកិច្ចព្រមព្រៀងនេះ ។ ជាចុងក្រោយ ដោយសារសេវារបស់យើង ផ្តល់ជូន ២៤ ម៉ោងក្នុងមួយថ្ងៃ តាមប្រព័ន្ធអ៊ីនធឺណិត **អ្នក ត្រូវការពារប្រព័ន្ធកុំព្យូទ័ររបស់អ្នកពីការវាយប្រហារដោយសារមេរោគ (Viruses) ឬអ្នកដែលលួចប្រើប្រព័ន្ធខុសច្បាប់ (Hackers) មុននឹងអ្នកប្រើសេវា នេះ** ។

### ១. សេវា

**១.១.** សេវាដែលយើងយល់ព្រមផ្តល់អោយក្រោមកិច្ចព្រមព្រៀងនេះ គឺការបញ្ជូនទិន្នន័យក្នុងល្បឿនលឿនតាមរយៈ*បច្ចេកវិទ្យាតាមវិធីអ៊ីនធឺណិតគ្មានខ្សែ (Wireless Internet Protocol-"WIP")* និងសេវាដទៃទៀត ដែលមានរៀបរាប់នៅ ក្នុងកិច្ចព្រមព្រៀងនេះ (**សេវា**) ។

**១.២.** សេវាពុំមានរួមបញ្ចូលឧបករណ៍ ឬសំភារៈចាំបាច់នានា សំរាប់អ្នកក្នុងការភ្ជាប់ និងប្រើប្រាស់សេវាទេ ។ អ្នកត្រូវជួល*ឧបករណ៍ដំឡើងខាងក្រៅផ្ទះ (អង់តែន) និងឧបករណ៍ដំឡើង (ប្រអប់ល្បឿន)* ("**ឧបករណ៍បញ្ជូនពត៌មាន**") នៅក្រោមលក្ខខណ្ឌនេះ ដូចមានចែងនៅក្នុងប្រការ ៣ ព្រមទាំងបង្គោលអង់តែន ខ្សែកាប និងគ្រឿងបន្ទាប់បន្សំចាំបាច់ផ្សេងៗ ។

**១.៣.** អ្នកត្រូវផ្តល់ឧបករណ៍ផ្សេងៗទៀតដែលចាំបាច់ ដើម្បីអោយអ្នកអាចប្រើសេវានេះបាន រួមទាំងឧបករណ៍សំរាប់ភ្ជាប់បណ្តាញ ភីស៊ី*អេធឺណេតកាត* (PC Ethernet Card), ណេតវើកកាត (Network Card) ឬឧបករណ៍តភ្ជាប់ Server ព្រមទាំងការផ្គត់ផ្គង់ថាមពល ដែល ការពារដោយអាំងវ៉ិចទ័រសំរាប់ទប់ចរន្ត (UPS) ដែលមានគុណភាពល្អ ។ ការផ្គត់ផ្គង់ចរន្តដែលគ្មានការរំខាន ត្រូវមាន អាំងវ៉ិចទ័រសំរាប់ទប់ចរន្ត (UPS) ។ ឧបករណ៍បញ្ជូនពត៌មាន ត្រូវបានធ្វើឡើងសំរាប់ប្រើប្រាស់ជាមួយចរន្តអគ្គិសនី ២២០ វ៉ុល + ១០%-១៥% ។

**១.៤.** យើងនឹងភ្ជាប់សេវាជូនអ្នក លុះត្រាតែអ្នកបានដំឡើងឧបករណ៍ចាំបាច់ទាំងអស់ រួចជាស្រេចតាមតំរូវការ។ អ្នកត្រូវធានា ថាការផ្គត់ផ្គង់ចរន្តចំពោះឧបករណ៍បញ្ជូនពត៌មាន ត្រូវមានភាពសមស្របជាមួយលក្ខណៈបច្ចេកទេសរបស់យើង។ អ្នកត្រូវថែរក្សាឧបករណ៍បញ្ជូនពត៌មានអោយដំណើរការបានល្អ ដើម្បីអោយយើងអាចផ្តល់សេវាដល់អ្នក ដោយអ្នក ជាអ្នកទទួលបន្ទុកលើការចំណាយសំរាប់ការថែរក្សានេះ ។

១.៥. អ្នកត្រូវយល់ព្រមថាមិនភ្ជាប់ឧបករណ៍ណាមួយ ក្រៅពីឧបករណ៍បញ្ជូនពត៌មានដែលជួលពីយើង ទៅអោយកន្លែងចែកចាយដែលដំឡើងវាសំរាប់ផ្តល់សេវាឡើយ ។ អ្នកមិនត្រូវកែប្រែឧបករណ៍បញ្ជូនពត៌មាន តាមរបៀបណាមួយឡើយ ។

១.៦. យើងនឹងដំឡើងឧបករណ៍ដែលអ្នកបានជួលពីយើង ហើយធានាថាឧបករណ៍នេះដំណើរការល្អទាំងស្រុង ។ អ្នកត្រូវទទួលរាល់ លិខិតអនុញ្ញាតចាំបាច់នានា ដើម្បីអោយយើង ឬភ្នាក់ងាររបស់យើងអាចចេញចូលអាគារ និងដំឡើងឧបករណ៍នេះដោយស្របច្បាប់។ តាមរយៈការស្នើយើងអោយដំឡើងឧបករណ៍បញ្ជូនពត៌មាននៅក្នុងអាគាររបស់អ្នក អ្នកអនុញ្ញាតឱ្យយើងប្រើប្រាស់ទីកន្លែងហើយទីកន្លែងទាំងនេះ មានភាពសមស្របសំរាប់ការ ដំឡើងនេះ ។ អ្នកត្រូវធានាថារចនាសម្ព័ន្ធ ដែលឧបករណ៍បញ្ជូនពត៌មានត្រូវដំឡើង មានភាពសមស្របសំរាប់ការដំឡើងដោយពុំ មានការខូចខាតចំពោះរចនាសម្ព័ន្ធនោះឡើយ។ យើងឬភ្នាក់ងាររបស់យើង នឹងមិនទទួលខុសត្រូវចំពោះការខូចខាត រចនាសម្ព័ន្ធឬ ការគ្រោះថ្នាក់ផ្ទាល់ខ្លួនរបស់អ្នកដែលបណ្តាលមកពីឧបករណ៍បញ្ជូនពត៌មានឡើយ។ យើងក៏មិនទទួលខុសត្រូវ ចំពោះដំណើរការនូវឧបករណ៍ ឬប្រព័ន្ធ ផ្សេងៗទៀត ដែលភ្ជាប់ទៅនឹងឧបករណ៍បញ្ជូនពត៌មានឡើយ ។

១.៧. យើងមិនធានាថា យើងនឹងផ្តល់សេវានៅកន្លែង ឬអាគាររបស់អ្នក ដោយជោគជ័យនោះទេ ។ ការខកខានបែបនេះគឺបណ្តាលមកពីមូលហេតុមួយចំនួន ដែលរួមទាំងទីតាំងអាគារ រចនាសម្ព័ន្ធ និងទីតាំងដែលអ្នកមាន សំរាប់ការដំឡើងនូវឧបករណ៍បញ្ជូនពត៌មាននេះ ព្រមទាំងលក្ខណៈនៃប្រព័ន្ធកុំព្យូទ័ររបស់អ្នក ឬឧបករណ៍តភ្ជាប់ដទៃទៀត ។ ប្រសិនបើយើងមិនអាចផ្តល់សេវាជូនអ្នក ដោយសារហេតុផលណាមួយ ក្រោយពីអ្នកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ យើងនឹងមិនទទួលខុសត្រូវចំពោះអ្នក ឬភាគីដទៃទៀត តាមរបៀបណាមួយឡើយ ។

១.៨. យើងអាចផ្តល់សេវាបន្ថែមផ្សេងៗទៀត ដែលអាចគិតថ្លៃដាក់លាក់។ ក្នុងករណីផ្តល់សេវាបែបនេះ យើងនឹងជូនដំណឹង ជាលាយលក្ខណ៍អក្សរដល់អ្នកអំពីសេវាបែបនោះ ហើយអ្នកនឹងមានជំរើសក្នុងការទទួលយក សេវាបែបនេះឬទេ ។

១.៩. សេវានឹងត្រូវគិតចាប់ពីថ្ងៃដែលសញ្ញារលកវិទ្យុ ត្រូវបានបញ្ជូនពីប្រព័ន្ធកុំព្យូទ័ររបស់អ្នកមកកាន់ប្រព័ន្ធរបស់យើងតាមរយៈឧបករណ៍បញ្ជូនពត៌មាន (" *កាលបរិច្ឆេទប្រើប្រាស់* ") ។

## ២. ការការពារប្រព័ន្ធកុំព្យូទ័ររបស់អ្នក

២.១. យើងនឹងខិតខំប្រឹងប្រែងអស់ពីលទ្ធភាពរបស់យើង ក្នុងការការពារពត៌មានសំងាត់របស់អ្នកក្នុងការប្រើប្រាស់សេវានេះ ។ ទោះបីជាយ៉ាងណាក្តី យើងមិនធានាចំពោះការរក្សាភាពសំងាត់ និងទទួលបន្ទុកចំពោះការធ្លាយពត៌មានសំងាត់ ដោយសារមូលហេតុណាមួយឡើយ ។

២.២. អ្នកគួរត្រូវយល់ដឹងថា សេវានេះអាចធ្វើអោយប្រព័ន្ធកុំព្យូទ័ររបស់អ្នកប្រឈមទៅនឹងមេរោគ កម្មវិធីបង្កើតមេរោគដើម្បីបំផ្លាញប្រព័ន្ធកុំព្យូទ័រការលួចចូលប្រើបណ្តាញដោយខុសច្បាប់(viruses,worms,trojans and hacking) និងការរំខានទូទៅចំពោះបណ្តាញកុំព្យូទ័ររបស់អ្នក។ **អ្នកត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការការពារប្រព័ន្ធរបស់អ្នកពីការវាយប្រហារបែបនេះ ដោយប្រើកម្មវិធីការពារការលួចប្រើបណ្តាញ និងកម្មវិធីប្រឆាំងនឹងមេរោគ និងក្នុងការ**

**ចាត់វិធានការការពារចាំបាច់ដទៃទៀត ។ យើងនឹងមិនទទួលខុសត្រូវចំពោះការវាយប្រហារ ឬការបំពានលើសុវត្ថិភាពតាមប្រព័ន្ធអេឡិចត្រូនិកបែបនេះឡើយ ទោះបីជាអ្នកបានរៀបចំបណ្តាញការពារក៏ដោយ ។**

## ៣. ថ្លៃឈ្នួលសេវាសំរាប់ការប្រើប្រាស់ឧបករណ៍បញ្ជូនពត៌មាន

៣.១ ជាមួយនឹងការយល់ព្រមរបស់អ្នកចំពោះ*កិច្ចព្រមព្រៀងអតិថិជនតេឡេស៊ីហ្វ* :

(ក) អ្នកយល់ព្រមជួលពីយើងនូវឧបករណ៍បញ្ជូនពត៌មានសំរាប់ចិរវេលានៅក្នុងកិច្ចព្រមព្រៀងនេះ ដែលគិតចាប់ពីកាលបរិច្ឆេទប្រើប្រាស់បណ្តាញ ។ អ្នកក៏យល់ព្រមផងដែរចំពោះការបង់ថ្លៃឈ្នួលឧបករណ៍ដំបូងដល់យើងក្នុងទឹកប្រាក់ដូចបានរៀបរាប់នៅក្នុង*កិច្ចព្រមព្រៀងអតិថិជនតេឡេស៊ីហ្វ* (ថ្លៃឈ្នួលឧបករណ៍ដំបូង) ។

(ខ) នៅក្នុងចិរវេលានៃកិច្ចសន្យានេះ ឧបករណ៍បញ្ជូនពត៌មាននៅតែជាកម្មសិទ្ធិរបស់ក្រុមហ៊ុនតេឡេស៊ីហ្វ ។

(គ) ប្រសិនបើអ្នក ឬយើងបញ្ចប់កិច្ចព្រមព្រៀងនេះ ក្រោមប្រការ ៥ ការជួលរបស់អ្នកនូវឧបករណ៍បញ្ជូនពត៌មានក៏នឹងត្រូវបញ្ចប់ដែរ ហើយអ្នកត្រូវអនុញ្ញាតអោយភ្នាក់ងាររបស់យើងចូលទៅកាន់អាគាររបស់អ្នកដើម្បីដោះយកឧបករណ៍បញ្ជូនពត៌មានក្នុងរយៈពេលបីថ្ងៃ ក្រោយពីការបញ្ចប់នេះចូលជាធរមាន ។ យើងសូមរក្សាសិទ្ធិក្នុងការចាត់វិធានការបន្ថែមដែលគិតថាចាំបាច់ ប្រសិនបើមានការបដិសេធន៍ចំពោះការដោះយកឧបករណ៍តាមកាលកំណត់ ។

(ឃ) អ្នកត្រូវយល់ព្រមរក្សានូវឧបករណ៍បញ្ជូនពត៌មានអោយស្ថិតក្នុងស្ថានភាពស្អាត ជាទីពេញចិត្ត ល្អ និងអាចដំណើរការបាន (លើកលែងតែមានការសឹករិចរឹលធម្មតា) ហើយមិនត្រូវអនុញ្ញាតអោយបុគ្គលណាម្នាក់ ក្រៅពីយើង ឬភ្នាក់ងាររបស់យើងធ្វើការជួលជុល ឬប្តូរទីតាំងឧបករណ៍បញ្ជូនពត៌មានឡើយ ។ អ្នកយល់ព្រមថានឹងផ្តល់ពត៌មានដល់យើងជាបន្ទាន់ នៅពេលដែលការជួសជុល ឬការកែសំរួលណាមួយមានភាពចាំបាច់ដើម្បីថែរក្សាឧបករណ៍បញ្ជូនពត៌មានអោយដំណើរការប្រក្រតី ។

(ង) អ្នកត្រូវទទួលបន្ទុកចំពោះចំណាយលើការជួសជុលទាំងអស់ និងតំរូវអោយយើង ឬភ្នាក់ងាររបស់យើងធ្វើការជួសជុលបែបនេះ ផ្ទាល់មុខ ព្រមទាំងបង់ថ្លៃសេវាសមស្របដល់យើង ។ យើងយល់ព្រមផ្លាស់ថ្មី ឬជួលជុលឧបករណ៍ដោយមិនគិតថ្លៃ ក្នុងករណីដែលមានការខូចឧបករណ៍ដែលបណ្តាលមកពីការផលិត ឬការដំឡើងដែលជះឥទ្ធិពលអវិជ្ជមានទៅលើសមត្ថភាពរបស់សេវា ។

(ច) អ្នកត្រូវអនុញ្ញាតអោយយើង ឬភ្នាក់ងាររបស់យើងចេញចូលកន្លែងដំឡើងឧបករណ៍បញ្ជូនពត៌មាន ដោយសេរី ដើម្បីយើងអាចពិនិត្យ និងជួសជុលឧបករណ៍បញ្ជូនពត៌មានក្នុងរយៈពេលបីថ្ងៃ បន្ទាប់ពីបានទទួលការជូនដំណឹងមកយើង ។

(ឆ) យើងនឹងខិតខំអោយអស់លទ្ធភាពក្នុងការដំឡើងឧបករណ៍បញ្ជូនពត៌មាននៅអាគាររបស់អ្នក ក្នុងរយៈពេល ២០ ថ្ងៃតាមប្រតិទិន បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។ ប្រសិនបើអ្នកបានបង់ថ្លៃឈ្នួលដំបូងទាំងអស់គ្រប់ចំនួន ក្រោមកិច្ចព្រមព្រៀងនេះ អ្នកនឹងត្រូវបានផ្តល់សេវា ។ អ្នកនឹងមិនត្រូវបានតំរូវអោយបង់ថ្លៃឈ្នួលដំបូង មុនកាលបរិច្ឆេទប្រើប្រាស់បណ្តាញឡើយ ។

## ៤. ថ្លៃឈ្នួលក្នុងការផ្តល់សេវា និងការដំឡើងឧបករណ៍បញ្ជូនពត៌មាន

៤.១. សំរាប់ការតភ្ជាប់សេវា និងការផ្គត់ផ្គង់នៅក្នុងកំឡុងមួយខែ ឬកន្លះខែដំបូង អ្នកត្រូវបង់ថ្លៃឈ្នួលដូចខាងក្រោម ក្នុងតំលៃ ដូចបានរៀបរាប់នៅក្នុង *កិច្ចព្រមព្រៀងអតិថិជនតេឡេសឺហ្វ* ("ថ្លៃឈ្នួលដំបូង") :

(ក) ថ្លៃសេវាប្រចាំខែគិតតាមការប្រើប្រាស់ជាក់ស្តែង សំរាប់ការផ្តល់ផែនការសេវា ដែលគិតចាប់ពីកាលបរិច្ឆេទប្រើប្រាស់បណ្តាញ

(ខ) ថ្លៃឈ្នួលផែនការទិន្នន័យសំរាប់ការផ្តល់ផែនការទិន្នន័យ

(គ) ថ្លៃឈ្នួលដំឡើងសំរាប់ការដំឡើងឧបករណ៍បញ្ជូនពតិមាន

(ឃ) ថ្លៃឈ្នួលឧបករណ៍ដំបូងសំរាប់ការប្រើប្រាស់ឧបករណ៍បញ្ជូនពតិមាន ដូចមានរៀបរាប់នៅក្នុងប្រការ ៣ នៃកិច្ចព្រមព្រៀងនេះ

(ង) ថ្លៃឈ្នួលដទៃទៀតដែលអាចត្រូវបានយល់ព្រម ចំពោះករណីពិសេសនានា ។

៤.២. សំរាប់សេវានៅខែបន្តបន្ទាប់នីមួយៗរហូតដល់ការបញ្ចប់សេវា ក្រោមប្រការ ៥ អ្នកត្រូវបង់ថ្លៃឈ្នួលដូចខាងក្រោម ("ថ្លៃឈ្នួលប្រចាំខែ") :

(ក) ថ្លៃសេវាប្រចាំខែ សំរាប់ការផ្តល់ផែនការសេវារបស់យើង

(ខ) ថ្លៃឈ្នួលទិន្នន័យប្រចាំខែ សំរាប់ការផ្តល់ផែនការទិន្នន័យ

(គ) ថ្លៃឈ្នួលឧបករណ៍បញ្ជូនពតិមាន ដូចមានរៀបរាប់នៅក្នុងប្រការ ៣ នៃកិច្ចព្រមព្រៀងនេះ

៤.៣. បន្ទាប់ពីការភ្ជាប់ឧបករណ៍បញ្ជូនពតិមានទៅកាន់សេវា អ្នកអាចប្រើសេវាដោយបង់ថ្លៃឈ្នួលទាំងអស់ និងគោរពតាមខ និងលក្ខខណ្ឌទាំងអស់នៃកិច្ចព្រមព្រៀងនេះ ។

៤.៤. អ្នកអាចប្តូរផែនការសេវារបស់អ្នក ក្នុងអំឡុងខែធ្វើអាជីវកម្ម តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់ *តេឡេសឺហ្វ* ។ ក្នុងករណីនេះ ថ្លៃឈ្នួលនឹងត្រូវគិតតាមការប្រើប្រាស់ជាក់ស្តែង ចាប់ពីកាលបរិច្ឆេទនៃការប្តូរផែនការសេវា ហើយថ្លៃឈ្នួលរដ្ឋបាលក៏នឹងត្រូវរួមបញ្ចូលផងដែរ ។

៤.៥. អ្នកក៏អាចផ្លាស់ប្តូរផែនការទិន្នន័យ ក្នុងអំឡុងខែធ្វើអាជីវកម្ម តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់ *តេឡេសឺហ្វ* ។ ក្នុងករណីនេះ ការកើនឡើង ឬថយចុះនូវថ្លៃឈ្នួលផែនការទិន្នន័យ នឹងត្រូវបានអនុវត្តរួម ទាំងថ្លៃឈ្នួលរដ្ឋបាល យោងតាមថ្លៃឈ្នួលដែលមាននៅក្នុងអត្ថបទបោះពុម្ពផ្សាយរបស់តេឡេសឺហ្វ ។

៤.៦. ការផ្លាស់ប្តូរចំពោះផែនការសេវា ឬទិន្នន័យ នៅខែបន្ទាប់ អាចធ្វើឡើងបាន តាមរយៈវិបសាយរបស់តេឡេសឺហ្វ (www.telesurf.com.kh) ។ ក្នុងករណីនេះ ពុំមានគិតថ្លៃឈ្នួលរដ្ឋបាលទេ ។

**៤.៧.** នីតិវិធីបង់ប្រាក់ និងពន្ធអាករ។ រាល់ថ្លៃឈ្នួលនៅក្នុងកិច្ចព្រមព្រៀងនេះ (រួមទាំងថ្លៃឈ្នួលដំបូង និងថ្លៃឈ្នួលប្រចាំខែ) ត្រូវបង់អោយយើង មិនអោយហួសពី ៧ ថ្ងៃ តាមប្រតិទិន ក្រោយពីកាលបរិច្ឆេទនៃការចេញវិក្កយបត្រ។ រាល់ថ្លៃឈ្នួលទាំងអស់ត្រូវបង់លើអាករលើតម្លៃបន្ថែម និងពន្ធផ្សេងៗទៀត ដែលអ្នកត្រូវបង់តាមច្បាប់កំណត់។ ការបង់ប្រាក់ត្រូវធ្វើឡើងនៅអាស័យដ្ឋានរបស់យើង ដែលមានសរសេរនៅក្នុង *កិច្ចព្រមព្រៀងអតិថិជនតេឡេសឺហ្វ* ឬតាម ការជូនដំណឹងចំពោះអ្នក ។ រាល់ថ្លៃឈ្នួលទាំងអស់ គឺមិនអាចប្រគល់ជូនវិញបានទេ ចាប់ពីថ្ងៃប្រើប្រាស់បណ្តាញ។ ក្នុងករណីដែលយើងមិនអាចផ្តល់សេវាដល់អ្នក តេឡេសឺហ្វនឹងត្រូវបានអនុញ្ញាតអោយរុះរើឧបករណ៍បញ្ជូនពតិមានទាំងអស់ដែលមិនទាន់ខូចខាតដែលជាកម្មសិទ្ធិរបស់យើង។

រាល់វិក្កយបត្រទាំងអស់ នឹងត្រូវបានផ្ញើតាមអ៊ីម៉ែលដល់អ្នក តាមអាស័យដ្ឋានអ៊ីម៉ែលរបស់អ្នក ដូចមានបង្ហាញនៅក្នុង*កិច្ចព្រមព្រៀងអតិថិជនតេឡេស៊ីហ្វ* ។

## ៥. ការបញ្ឈប់ ឬផ្អាកសេវា

៥.១. ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវស្ថិតក្រោមសេចក្តីណែនាំដែលអាចផ្តល់ម្តងម្កាលដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (“MPTC”) ឬស្ថាប័នក្រោមបង្គាប់របស់ក្រសួង ។ អ្នកទទួលស្គាល់ថា យើងប្រតិបត្តិការងារក្រោមបទបញ្ជារបស់ MPTC ក្នុងការផ្តល់សេវា និងថារាល់ការផ្លាស់ប្តូរទាំងឡាយទៅលើបទបញ្ជារបស់ MPTC ដោយសារហេតុផលណាមួយ អាចនាំមកនូវការបញ្ឈប់កិច្ចព្រមព្រៀងនេះ ដោយគ្មានការផាកពិន័យចំពោះភាគីណាមួយឡើយ ។

៥.២. ភាគីទាំងពីរអាចបញ្ឈប់សេវា ដោយសារហេតុផលណាមួយ ដោយផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន រយៈពេល ៧ ថ្ងៃ ដល់ភាគីម្ខាងទៀត ។ ប្រសិនបើអ្នកបញ្ឈប់កិច្ចសន្យា ពុំមានការផ្តល់ប្រាក់ជូនវិញទេ ហើយអ្នកត្រូវបង់ថ្លៃឈ្នួលប្រចាំខែក្នុងអំឡុងរយៈពេលជូនដំណឹង ។ ប្រសិនបើយើងបញ្ឈប់ការផ្តល់សេវាក្រោមប្រការនេះ យើងនឹងផ្តល់ប្រាក់ជូនអ្នកវិញ សំរាប់ចំណែកនៃថ្លៃឈ្នួលសេវាប្រចាំខែ ដែលមិនទាន់បានប្រើ ។ ក្នុងករណីទាំងពីរនេះ អ្នកត្រូវប្រគល់ឧបករណ៍បញ្ជូនពតិមានដែលជាកម្មសិទ្ធិរបស់យើង អោយយើងវិញ ហើយត្រូវបង់ទឹកប្រាក់ដែលនៅជំពាក់ មុនកាលបរិច្ឆេទបញ្ឈប់សេវា ។

៥.៣. យើងមានសិទ្ធិទាំងស្រុងក្នុងការផ្អាក ឬបញ្ឈប់សេវា ដោយមិនចាំបាច់ជូនដំណឹង ក្រោមស្ថានភាពដូចខាងក្រោម :

(ក) ប្រសិនបើយើងគិតថា សេវាកំពុងត្រូវបានប្រើក្នុងគោលបំណងខុសច្បាប់ ឬ

(ខ) ប្រសិនបើអ្នកមិនគោរពតាមប្រការណាមួយ នៃកិច្ចព្រមព្រៀងនេះ រួមទាំងការខកខានក្នុងការបង់ថ្លៃឈ្នួលដំបូង ឬថ្លៃឈ្នួលប្រចាំខែអោយបានទាន់ពេលទេនោះ ឬ

(គ) ពតិមាន ឬឯកសារដែលអ្នកផ្តល់អោយ នៅពេលចុះកិច្ចព្រមព្រៀងនេះ ត្រូវបានរកឃើញថាជាឯកសារក្លែងក្លាយ ឬ មានពតិមានដែលធ្វើអោយយល់ច្រឡំ ។

**ប្រសិនបើយើងផ្តាច់ ឬបញ្ឈប់សេវាដោយពុំមានការជូនដំណឹង ដោយសារហេតុផលទាំងនេះ យើងមិនទទួលខុសត្រូវចំពោះការទាមទារ ដែលកើតចេញពីការផ្តាច់សេវានេះឡើយ ។ អ្នកពុំមានសិទ្ធិទទួលប្រាក់សំណងវិញចំពោះថ្លៃឈ្នួលប្រចាំខែ ឬថ្លៃឈ្នួលដំបូងទេ នៅក្នុងករណីបែបនេះ ។** អ្នកនៅតែត្រូវបង់ថ្លៃឈ្នួលប្រចាំខែក្នុងអំឡុងពេលផ្តាច់នេះ ។ ប្រសិនបើយើងយល់ព្រមផ្តល់សេវាដល់អ្នកជាថ្មីបន្ទាប់ពីការផ្តាច់នេះ អ្នកនឹងត្រូវបង់ថ្លៃឈ្នួលតភ្ជាប់សេវាឡើងវិញ ។

## ៦. បញ្ហាផ្សេងៗ

៦.១. **អ្នកទទួលស្គាល់ថាសេវានេះ ត្រូវបានផ្តល់ដោយគ្មានការធានាថាសេវានេះដំណើរការជាប់រហូតដោយគ្មានការអាក់ខានទេ** ។ យើងមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតណាមួយ ដែលកើតចេញពីការខកខានក្នុងការផ្តល់សេវា ឬពតិមាន ឬសារណាមួយដែលបញ្ជូនដោយសេវានេះ ឬការរំខានខុសច្បាប់នូវពតិមាន ឬសារបែបនេះណាមួយឡើយ ។ យើងមិនទទួលខុសត្រូវចំពោះការខកខាន ឬការពន្យារពេលក្នុងការជួសជុល ឬដាក់ឧបករណ៍ ឬគ្រឿងបន្ទាប់បន្សំថ្មី នៅពេលដែលការខកខាន ឬពន្យារពេលបែបនេះ ហួសពីការគ្រប់គ្រងរបស់យើង ។ ការទាមទារណាមួយពីយើង

ដែលអ្នកធ្វើឡើងទាក់ទិនទៅនឹងបញ្ហាណាមួយដែលកើតចេញពីកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលដប់បួន (១៤) ថ្ងៃ ចាប់ពីព្រឹត្តិការណ៍ដែលការទាមទារត្រូវបានធ្វើឡើង ហើយប្រសិនបើអ្នកខកខានមិនបានធ្វើការជូនដំណឹងក្នុងរយៈពេលនេះទេនោះ យើងចាត់ទុកថាអ្នកបោះបង់សិទ្ធិក្នុងការទាមទារសំណងបែបនេះ ។

៦.២. គ្មានការខកខានឬការពន្យារពេលរបស់យើងណាមួយក្នុងការអនុវត្តន៍នូវខនិងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដែលនឹងប៉ះពាល់ដល់សិទ្ធិ និងអំណាចរបស់យើងក្រោមកិច្ចព្រមព្រៀងនេះឡើយ ឬគ្មានការបោះបង់សិទ្ធិណាមួយរបស់យើងចំពោះការរំលោភរបស់អ្នកលើកិច្ចព្រមព្រៀងនេះ ត្រូវបានចាត់ទុកថាជាការបោះបង់សិទ្ធិចំពោះការរំលោភបំពានបន្តបន្ទាប់របស់អ្នកឡើយ ។

៦.៣. ប្រសិនបើអ្នករើទីតាំងទៅកន្លែងថ្មី យើងមិនអាចធានាថា យើងអាចផ្តល់សេវានៅអាស័យដ្ឋានថ្មីនោះទេ ។ អ្នកត្រូវបង់ថ្លៃឈ្នួលសំរាប់ការរើនិងការដំឡើងជាថ្មីនូវឧបករណ៍បញ្ជូនពតិមាននិងសំរាប់ការភ្ជាប់សេវាឡើងវិញនៅអាស័យដ្ឋានថ្មី ។ ប្រសិនបើអ្នកចង់អោយយើងផ្តល់សេវា នៅទីតាំងមួយផ្សេងទៀតក្រៅពីទីតាំងដែលមានចែង នៅក្នុងកិច្ចព្រមព្រៀងនេះ អ្នកត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងដាច់ដោយឡែកមួយផ្សេងទៀតជាមួយយើងសំរាប់ការផ្តល់សេវានៅ ទីតាំងនោះ ។

៦.៤. យើងអាចកែប្រែលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ព្រមទាំងថ្លៃឈ្នួលនៅពេលណាមួយ តាមអ៊ីម៉េល ដែលយើងនឹងជូនដំណឹងដល់អ្នកអំពីការកែប្រែណាមួយ អោយបានយ៉ាងហោចណាស់រយៈពេល ៣០ ថ្ងៃ ជាមុន ។ ប្រសិនបើអ្នកមិនយល់ព្រមលើការកែប្រែនេះ អ្នកអាចបញ្ឈប់កិច្ចព្រមព្រៀងនេះបាន ប៉ុន្តែអ្នកត្រូវជូនដំណឹងដល់យើងអំពីការបញ្ចប់កិច្ចព្រមព្រៀងបែបនេះ ក្នុងរយៈពេល ១៤ ថ្ងៃ ក្រោយពីការជូនដំណឹងរបស់យើង ។ ប្រសិនបើអ្នកជូនដំណឹងដល់យើងថា អ្នកមានបំណងបញ្ឈប់កិច្ចព្រមព្រៀងនេះ ការបញ្ឈប់នេះនឹងមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការកែប្រែកិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាព ដូចបានបញ្ជាក់នៅក្នុងការជូនដំណឹងរបស់យើង ។ ប្រសិនបើអ្នកបានធ្វើការជូនដំណឹងស្តីពីការបញ្ឈប់កិច្ចព្រមព្រៀង ក្រោម ខ នេះ ហើយអ្នកនៅតែបន្តប្រើប្រាស់សេវានេះ ហួសកាលបរិច្ឆេទនៃការកែប្រែ អ្នកត្រូវបង់ថ្លៃឈ្នួលសំរាប់ការប្រើប្រាស់បែបនេះ ។

៦.៥. យើងមានសិទ្ធិផ្ទេរនូវសិទ្ធិណាមួយ ឬទាំងអស់របស់យើងក្រោមកិច្ចព្រមព្រៀងនេះ ទៅអោយភាគីមួយផ្សេងទៀត នៅពេលណាមួយក៏បាន ។ កិច្ចព្រមព្រៀងនេះផ្តល់សិទ្ធិដល់អ្នកតែម្នាក់ប៉ុណ្ណោះ ហើយអ្នកមិនអាចប្រគល់ ឬផ្តល់សិទ្ធិណាមួយ ក្រោមកិច្ចព្រមព្រៀងនេះ ដល់បុគ្គល ឬអង្គភាពណាមួយផ្សេងឡើយ ។

៦.៦. កិច្ចព្រមព្រៀងនេះគឺជាកិច្ចព្រមព្រៀងទាំងមូល និងរួម ចំពោះភាគីទាំងពីរ ហើយមិនអាចត្រូវបានធ្វើការកែប្រែឡើយ លើកលែងតែតាមរយៈការសរសេរជាលាយលក្ខណ៍អក្សរដោយយើង ដូចមានចែងនៅក្នុងកិច្ចសន្យានេះ ។

៦.៧. កិច្ចព្រមព្រៀងនេះ និងរាល់ការកែប្រែទាំងអស់ត្រូវបានធ្វើឡើងជាភាសាអស់គ្លេស ។ រាល់ការជូនដំណឹងទាំងអស់ដែលចាំបាច់ក្រោមកិច្ចព្រមព្រៀងនេះ អាចធ្វើឡើងជាភាសាអង់គ្លេស ឬភាសាខ្មែរ ហើយត្រូវផ្ញើតាមអ៊ីម៉េលទៅកាន់អាស័យដ្ឋានអ៊ីម៉េលដែលមានសរសេរនៅក្នុង*កិច្ចព្រមព្រៀងអតិថិជនតេឡេស៊ីហ្វ* ឬអាស័យដ្ឋានដែលបានប្តូរ ដោយមានការជូនដំណឹងដល់ភាគីម្ខាងទៀត ។

៦.៨. ប្រសិនបើប្រការណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានចាត់ទុកថាគ្មានសុពលភាព ឬមិនអាចអនុវត្តបាន កិច្ចព្រមព្រៀងនេះត្រូវអនុវត្តដដែល ដោយលើកលែងប្រការដែលគ្មានសុពលភាពទាំងនេះ ។

៦.៩. កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។